Khmer Story Lovers

# បញ្ហាមរណៈ

— ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៥ ផ្លូវលេខ ២៧៥ ជីឡូត៍លេខ ២៥៨ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នកប្រែសម្រួល: អ.គីមសាន

តម្លៃ ៣៖០០

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
« មាតុភូមិ »
ភ្នំពេញ

លេខ ២៧

ឈុនស៊ីឃើញមាណពពោលពាក្យល្ងង់ខ្លៅ របៀបកូនក្មេងបែបនេះ គាត់នឹកខឹងផង អស់សំណើចផង ធ្វើហ៊ឹះ ៗ នៅចុងច្រមុះ រួចថយក្រោយពីរជំហាន បុកដាវកក់ក្នុងជីវង់ចាំ ព្រមពោលបញ្ចេច :

–ឯងស្មានថាឥសីឈុនស៊ីជាមនុស្សធុនណា? ហ៊ានវាយធ្លាក់ការប្រមាថឯង ?

គាត់ឈរច្រត់ដៃទាំងពីរលើចង្កេះ រង់ចាំមាណពរើសកាំបិត ដណ្ដឹងសួរក្នុងចិត្តថា :

–កាត្តុបនេះប្រើកាំបិតជាការុធអីចឹង មិនមែនជាសិស្សក្ដីប្រពន្ធប្អូនស៊ីទេ ៗ . មិនដឹងហេតុអីប្អូនប្រុសប្អូនស្រីប្រើវាឲ្យហៅយើងថាគ្រូអ៊ីគ្រូមា ?

ចំណែកស៊ីផានទុនរើសកាំបិតបណ្ដើរបែកគំនិតមួយបណ្ដើរ:

–បើយើងមិនប្រយ័ត្នច្រឡំដៃវាយឥសីស្លាប់ម្នាក់ទៀតទេដឹង? ល្ហើយ ! ដើម្បីចៀសវាងផលការក្រក់ត្រូវចងដៃម្ខាងទុកសិន ទើបមិនពិបាកចិត្ត ៗ

មាណពគិតឃើញស្រួលហើយ ទើបក្រោកឈរស្រែកប្រាប់ឥសីឈុនស៊ីថា :

–សូមអត់ទោស, មេត្តារង់ចាំបន្តិចសិន !

នាយស្រាយខ្សែពីចង្កេះ, ទម្លាក់ដៃឆ្វេងតាមបណ្ដោយខ្លួ

ហើយដៃស្ដាំចាប់ខ្សែពីចង្កេះចងក្រៀកដៃម្ខាងនោះជាប់នឹងដងខ្លួនយ៉ាងមាំ ។ ឥសីទាំងអស់ព្រមទាំងប្ដីប្រពន្ធស៊ីឈីងបើកភ្នែកធំសំឡឹងមើលមាណពឥតយល់ថា នាយចង់សម្ដែងគាក់កំប្លែងអ្វីឡើយ ។ ស៊ីផានចងដៃម្ខាងជាប់ហើយ ទើបកាន់កាំបិតស្រែកថា :

– យើងសាកល្បងគ្នាមើល៍, ម្ដងនេះខ្ញុំមិនសម្លាប់លោកទេ ។

វាចានិងអាកប្បកិរិយានេះធ្វើឲ្យឥសីឈុនស៊ីខឹងសឹងសន្ធប់បាត់ស្មារតី ត្បិតគាត់យល់ថា មាណពចងដៃប្រយុទ្ធជាមួយគាត់បែបនេះជាកិច្ចប្រមាថគាត់ដល់កំរិត ។ ពពួកឥសីខាងអាស្រមសាំងឈីងក៏ខឹងក្រោធគ្រប់គ្នាដែរ, គេស្រែកជេរអ្នកកម្លោះគ្រប់ទិស ព្រូវ ហ៊ឹង ។ ស៊ីឈុីងនិងវុនយូស្រែកបន្ទោសមាណព :

– ម៉េចកូនឯងព្រហើនម៉្លេះ ? ស្រាយដៃចេញភ្លាមឡើង !

**ស៊ីផានកំពុងទីទើរ** មិនដឹងស្រាយចំណងដៃឆ្វេងឬមិនស្រាយ, ឥសីកុងស៊ីលើកដាវចាក់ភ្លែតមកហើយ ។ នាយលើកកាំបិតរងការពារភ្លាម តែឈុនស៊ីមិនបណ្ដោយឲ្យផ្លែដាវគាត់ប៉ះកាំបិតមាណពឡើយ ព្រោះគាត់ឃើញច្បាស់ថា «អាប្រមក់» មានកម្លាំងធាតុច្រើនសម្បើមណាស់ ។ គាត់ប្រញាប់ប្រែស្នៀតវាយលុកផ្លូនៗ ក្រាំមួយប្រាំពីរស្នៀតភ្លាម រកតែមាណពមើលមិនទាន់ផង កុំថាឡើយដល់រើកាត់ ។ នាយស្រឡាំងកាំងស្ងួនដៃស្ងួនជើង នឹកថាវីវរហើយជាន់ហ្នឹង ! ព្រមទាំងលើកកាំបិតវាយតែផ្ដេសផ្ដាស គ្មានក្បួនខ្នាតឬត្រឹមត្រូវតាមគុនកាំបិតមួយណាសោះ ។

ឥសីឈុនស៊ី ធ្លាប់ស្គាល់កម្លាំងធាតុនាយ ក៏នៅញញើតដដែល ទោះឃើញនាយសំដែងគុនកាំបិតគ្រវីគ្រវាត់គ្រប់ទិស ក៏ឥ.ប៊ីខំកាន់ដាវជាប់ម៉ឺង ឥតហ៊ានប៉ះកាំបិត ឬ ខ្យល់ដៃមាណពដែរ នឹកថាបើរបូតដាវពីដៃមុខជាខ្មាសគេបោះមុខដាន់ហ្នឹងហើយ ។

ស៊ីផានវាយគ្រប់ទិសតំបន់មួយសន្ទុះ ឃើញឥសីថយក្រោកៗ ទង់គេចវេះពេក នាយដកខ្លួនសម្រួលឥរិយាបថ និងពិចារណាស្រួលបួលដែរ ។ ភ្លាមនោះនាយនឹកឃើញស្នៀតគុនកាំបិតដែលបានហាត់ហ្វឹកហ្វឺនម្នាក់ឯងលើកោះផ្សែងខ្មៅ :

– យី ! គិតប្រើស្នៀតគុនដែលស្រាវជ្រាវរកឃើញខ្លួនឯងសាកមើល !

កាលណោះមាណពកាន់មែកឈើក្នុងដៃឆ្វេងជំនួសដាវ ដៃស្ដាំកាន់កាំបិត ។ ពេលនេះនាយចងដៃឆ្វេងជាប់ហើយមិនអាចប្រើគុនដាវរួមជាមួយគុនកាំបិតទេ ប៉ុន្តែដៃស្ដាំដែលនៅសល់នេះមានឥទ្ធិពល

ខ្លាំងក្លាក្រៃលែង សំដែងគុនកាំបិតថ្វៃកវអស្ចារ្យ ។ មាណពមានកម្លាំងកាយស្តុកស្តម្ភ តែហាត់រៀនម្នាក់ឯងដូចកូនក្មេងរៀនដើរមុនដំបូងម៉្លោះហើយស្នៀតនាយមានចំណុចខ្សោយច្រើនណាស់ បើកុំតែបានកម្លាំងធាតុជួយផ្សំបញ្ចូល ម៉្លេះសមស្នៀតគុនរបស់នាយមិនមានឥទ្ធិឫទ្ធិដល់ម្ល៉ឹងឡើយ ។

- ស៊ីផានសំដែងគុនកាំបិតបានប្រហែលជាប់ស្នៀត, ឥសីគ្រប់រូបព្រមទាំងប្ដីប្រពន្ធស៊ីឈីងងឿងឆ្ងល់គ្រប់គ្នា ។ ឥសីឈុនស៊ីតក់ស្លុតខ្ទិចខ្ទីងក្រោធជាងគេ កាន់តែព្រឺក្បាលកោតស្ញប់ស្ញែងមាណពដែលមានកម្លាំងធាតុដ៏កម្រប្រទះ ។ មុនដំបូងឥសីស្មានថាគុនកាំបិតនេះថ្មីថ្មោងណាស់ ហាក់គ្មានមូលដ្ឋានឫសគល់ច្បាស់លាស់ទេ ។ គាត់ធ្លាប់ដើរផ្សងព្រេងក្នុងពិភពគុនស្គាល់ស្នៀតគុនកាំបិតស្ទើរទាំងអស់ នឹកសង្ឃឹមថាអាចវាយបំបែកខ្យល់ដៃមាណពដូចបំណង ឥឡូវបែរជាមើលលែងយល់បំបែកលែងបានទៅវិញ ។

គេប្រយុទ្ធគ្នាបានប្រហែលជាប់ស្នៀតទៀត, ឥសីឈុនស៊ីរឹតតែខឹងក្រេវក្រោធ យារដាវចាក់ត្រូវពេលដែលស៊ីផានបង្វិលកាំបិតវាយរះមកដែរ ។ កាយវិការទាំងពីររហ័សនិងខ្លាំងក្លាដូចគ្នា, ដាវនិងកាំបិតទង្គិចគ្នា ចាំង ! ឥសីខំកាន់ដាវមិនឲ្យរបូតពីដៃ ។ អ្នកនៅជុំវិញស្រែកគ្នាអ៊ូអរឡើង... ឥសីឈុនស៊ីឃើញដាវគាត់កោងដូចផ្លែកណ្ដៀវ ហើយឈាមហូរពីបាតដៃប្រឡាក់ដងដាវក្រហមច្រាល, ត្បិតកម្លាំងធាតុមាណពរុញច្រានមកខ្លាំងពេកទាល់តែរហែកបាតដៃចេញឈាម ។ ឥសីឈុនស៊ីត្រូវរបួសប៉ុណ្ណេះ ក៏ត្រជាក់ខ្លួនស្រឹតនឹកថា :

– កិត្តិយស កិត្តិនាមយើងរលាយដូចអំបិលត្រូវទឹកទន្លេហើយ ! តើនៅហាត់ហ្វឹកហ្វឺនគុនវិជ្ជាដល់ណាទៀត ? សង្ឃឹមធ្វើនាយក្រុមអាស្រមសាំងឈីងម្ដេចកើត ?

រំពេចនោះឥសីឈឺចិត្តណែនទុកគ្រវាត់ដាវកោងក្ងុកចោលវ៉ឺ ហើយលូកដៃទាំងពីរលោតសង្គ្រុបលើស៊ីផានដោយស្នៀតចាប់ខ្មាំងម្ដង ។ មាណពរវល់លើកកាំបិតរងផ្លូវដាវកោងក្ងុកទុកទ្រូងចំហឲ្យឥសីចុចពិតបរសំខាន់ពីរកន្លែង ។

ឥសីបញ្ចេញរេកក្បួនកិរិយាការ ហាក់ចង់ប្រយុទ្ធយកស្លាប់រស់ជាមួយមាណពទើបសំដែងស្នៀតចាប់ខ្មាំងពិសេសនៃអាស្រមសាំងឈីង ។ គ្រាន់តែលូកដៃទាំងពីរប៉ះពិតបរស៊ីផានភ្លាម, ឥសីទទួលអារម្មណ៍ចំឡែកតឹកម្លាំងធាតុមាណពធាក់ខ្យល់ដៃឥសីចេញក្រៅវិញ ទាល់តែខ្លួនគាត់ប៉ើងខ្ពតទៅក្រោយយ៉ាងខ្លាំង ។

ត្បិតកាលលោកសម្រុកចូលទៅឆ្នាំមាតពណានោះ ឥសីស្ទុះចូលទាំងកំពុងបញ្ចេញកម្លាំងពលំ ម្ល៉ោះហើយពេលខ្នាតមកវិញ គាត់ត្រូវគ្រោះកាម៉ាស់មុខដោយដាច់ផ្ការ ឬដួលក្បុកគូទ... ក្នុងគ្រាប្រជុំ ញ៉ុំបនោះ ឥសីធានស៊ុំស្ទុះវៃ្កត លើកដៃម្ខាងប្រានស្លាប្អូនរូបគ្រាំលាយកម្លាំងបម្លែកបេញខ្លះ ទុកឲ្យកាស ឲ្យឥសីឈុនស៊ុំពោតឈរត្រង់ខ្លួនឡើងវិញ, តែមុខគាត់បម្លែកហាក់គ្មានឈាមមួយតំណក់សោះ ។

ឥសីធានស៊ីប្រានឈុនស៊ុំចេញហើយ . ដកដាវមកកាន់ ព្រមទាំងពោលមួយៗ :

– នេះបានបំផាន់អ្នកក្លាហានដ៏ក្មេង ! គួរស្ងើចសរសើរមែន ! យើងសុំសាកល្បងផងបានឬទេ ? ប្រហែលយើងចាស់ពេកកម្លាំងខ្សោយទប់ទល់មិនបានទេដឹង ? ពោលបប់ឥសីព្រួញដាវចាក់សន្សឹមៗទៅ ។ ស៊ុំផានប្រញាប់លើកកាំបិតវង់កាត់ក្បាម ហើយពេលនោះកម្លាំងធាតុទាំងប៉ុន្មានដែលជ្រាបចូលតាមកាំបិតមកក៏រលាយអស់រលីងដោយហេតុថា លោកឥសីធានស៊ីប្រើយុទ្ធសិល្បៈស្រូបកម្លាំងធាតុមាណពនោះឯង ។ ប៉ុន្តែគាត់ត្រូវស្ទុះដកដៃម្ខាងរហូតដល់ដើមទ្រូងវិញដែរ ។

ឥសីភ័យណាស់ស្មានថា គាត់មានរបួសក្នុងប្រាណដោយសារកម្លាំងធាតុដ៏ចម្លែកនេះហើយ មិនអាចវាយលុកជាលើកទីពីរទេ ។ បើមាណពកាប់សន្សមួយកាំបិតមកទៀតច្បាស់ជាគាត់គ្មានកម្លាំងឯណាជួនលួបសាកល្បងទេ ម្ល៉ោះហើយលោកឥសីត្រៀងខ្លួនគេចផុតយារដាវចាក់មាណពយ៉ាងរហ័ស ។ ឥសីធានស៊ុំអាយុជាងហុកសិបឆ្នាំហើយ អាចបញ្ចេញស្នៀតនិងកាយវិការរហ័សមិនចាញ់ក្មេង ហើយអាចបន្តការប្រយុទ្ធយ៉ាងស្វាហាប់គួរឲ្យសរសើរ ។

អ្នកទាំងពីរប្តូរយុទ្ធសិល្បៈបានជាងម្ភៃស្នៀតទៀត ក្នុងពេលដ៏ខ្លី ។ កម្លាំងខ្យល់ដាវនិងកាំបិតវាតទីកាន់តែធំឡើង ។ ធ្វើឲ្យអ្នកឈរមើលថយក្រោយជាលំដាប់ ។ ឥសីពីររូបដែលឈរឃ្លាំមើលប្តីប្រពន្ធស៊ុំឈឹងមិនឲ្យជួយស៊ុំផានទេនោះ ស្តាប់សូរខ្យល់អាវុធប្លែកគ្រប់បៀកពេក ក៏បោលភ្នែកមកមើលនឹងគេដែរ ។

ស៊ុំផានបញ្ចេញសុទ្ធតែស្នៀតគុនកាំបិតដែលនាយបានហាត់ហ្វឹកហ្វឺនលើកោះវៃជ្រងខ្មៅ ។ នាយសំដែងយូរទៅរឹតតែស្ទាត់ជំនាញឡើង, កម្លាំងធាតុរឹតតែកើនឡើងជាលំដាប់គួរចំឡែកណាស់ ។ មុនដំបូងឥសីធានស៊ុំអាចទប់ទល់បាន, ដល់យូរៗទៅគាត់ព្រួយបារម្ភព្រោះទាំទ្រដល់បាកបេះតែតើបប្រូចះនឹងកម្លាំងធាតុខ្លាំងក្លាចេញពីកាំបិតមាណពច្រើនឡើង ។ ដូចទឹកជ្រោះហូរពីលើភ្នំមិនចេះអស់មិនចេះហើយ ។ លោកឥសីច្បូកគុនដាវមែនតែដើងគាត់តាំងគូឈើស្ទុកម្តងបន្តិច, ដៃទាំងសងខាង

Khmer Story Lovers



ឈើចុកចាប់ខ្លាំងឡើងៗ, កាយវិការទាំងអម្បាលម៉ានយ៉ាំតយ៉ាវ . . .

ប្ដីប្រពន្ធស៊ុយឈីងតាមដានការប្រយុទ្ធយល់ថា បើបន្តទៅទៀតពិតជាឥសីធានស៊ុមានរបួស ហើយបើគាត់ស្រែកឃាត់កូនប្រុស វានៅជាបង្អាប់កូនឲ្យមានអត្យាស្រ័យលើកលែងនាយក្រុមសាំងឈីង រឹតតែមិនល្អមើលថែមទៀត ។ នៅចំពោះស្ថានការណ៍ដ៏លំបាកនេះស៊ុយឈីងនិងអ្នកស្រីវុនយូ ខ្វល់ខ្វាយចិត្តអន្ទះ អន្ទែងខ្លាំងណាស់មិនដឹងគិតយ៉ាងម៉េចឲ្យសុខសប្បាយទាំងអស់គ្នាទេ ។

ចំណែកស៊ុំផានប្រយុទ្ធយូរដក់ដៃរឹតតែសប្បាយរីករាយពេញចិត្តខ្លួនឯងជាអតិបរមា ។ វាយលុកឥតគិតអ្វីៗនៅជុំវិញខ្លួនឡើយ ។ ស្រាប់តែនាយឃើញឥសីទន់ដងខ្លួនបង្ហួលហើយគាត់ខំប្រឹងទប់ដំហរមុខឡើងស្វាំង ។ មាណពភ្ញាក់ក្រញាងនឹកដល់បណ្ដាំអាស៊ីវ ដែលប្រាប់ហើយប្រាប់ទៀតឲ្យចេះសន្ដោសប្រោសប្រណីគូប្រយុទ្ធក្នុងពេលគេចាញ់ ។ សំដីផ្អែមល្ហែមរបស់អាស៊ីវលាន់រងំត្រចៀកនាយថា "បើកាចចៀសវាងបានត្រូវសន្ដោស" . . . នឹកដល់បំដាំថ្ងៃចុះ នាយស្រវៃឃើញទាំងរូបរាងទឹកមុខនាងញញឹម ប្រិមប្រិយផ្ដាំនាយឲ្យចេះយោគយល់ អ្នកក្លាហានដូចគ្នាឲ្យចេះផ្ដួញមិត្តបន្ទុយសត្រូវ ។

មាណពភ្ញាក់ស្មារតី ហើយក៏យារគាំបិតកាប់វឹបវែបទៀត ។ ឥសីធានស៊ុពួសន្ធឹកខ្យល់ចង់ស្ទុះដង្ហើម ប្រញាប់ហក់ថយក្រោយពីរជំហានយ៉ាងប្រញាប់ ទាំងទ្រេតទ្រោតរេករលដួលខ្លាសតេៗ តែមាណពកាប់សំពងបន្ទុសទីដៅទៅវានក្ដេង រួចក្រឡាប់មកខាងស្ដាំ លើកកាំបិតសំពងពីមុខឥសី ជាលើកចុងក្រោយ ។ កាយវិការទាំងប៉ុន្មានមានឥទ្ធិពលខ្លាំងក្លា តែជាស្មៀតបញ្ឆោតទាំងអស់, ធូលីដីនិងស្លឹកឈើដាំប៉ះប៉ុងពាសពេញដូចគ្រូវខ្យល់ព្យុះ ធ្វើឲ្យឥសីធានស៊ុដកដង្ហើមញាប់ស្អេក ។ កំពុងតែភ័យបារម្ភនឹងគេតស្ងប់ស្ងៀម លោកឥសីឃើញមាណពថយក្រោយពីរជំហានលើកកាំបិតដាក់ទន្ទឹមទ្រូង ស្រែកខ្លាំង ១ ថា :

-លោកឥសីមានវិជ្ជាគុនដាវពូកែខ្ពង់ខ្ពស់ណាស់, ខ្ញុំសុំសរសើរដោយស្មោះ ។ ថ្ងៃនេះយើងប្រយុទ្ធមិនចាញ់មិនឈ្នះគួរផ្អាកបុណ្ណឹងចុះ, សុំគ្នាធ្វើមិត្តសំឡាញ់វិញ ។

នេះជាពាក្យបណ្ដាំរបស់អាស៊ីវ ។ ឥសីធានស៊ុស្ទើរមិនជឿ ក៏ស្រឡាំងកាំងហាមាត់និយាយលែងចេញ ។ ឥសីដទៃទៀត ព្រមទាំងប្ដីប្រពន្ធស៊ុយឈីងសង្កេតកាយវិការស្រស់សង្ហាដែលមាណពលើកកាំបិតដាក់ទន្ទឹមទ្រូងឈរស្ងៀមដូចក្នុងសមជាកំពូលអ្នកគុនទ័យមក្មេងខ្ចី គេពេញចិត្តណាស់ៗ

Khmer Story Lovers



បានទះដៃហៅក្រៅ ។

ស៊ីឈីនផកជង្ហើមយូរបន្តិចទ្រូង ញញឹមស្រស់, អ្នកស្រីវុនយូបញ្ចេញទៀតភ្នែកក៏ថា ទឹកមុខរីកស្រស់បំព្រិម ដូចបុប្ផារីកពេលព្រលឹម ។ ត្បិតពីនោកប្ដីប្រពន្ធនេះ ឃើញកូនប្រុសមានស្នាដៃខ្ពស់ ត្រដែតប្រយុទ្ធឈ្នះនាយក្រុមកាស្រមសាំងឈីង ជាពិសេសដោយឃើញកូនប្រុសបញ្ចេញអាកប្បកិរិយា ស្លូតបូត ពោលពាក្យគួរសមស្របនឹងសន្តានចិត្តគាត់ទាំងស្រុង ។

អ្នកស្រីវុនយូសើចក្អាកក្អាយ ស្រែកបន្ទោស:

- កូនចំកួតនិយាយផ្ដេសផ្ដាសម្ល៉េះ ! ... លោកប្ដី, ខ្ញុំប្ដី ? ម៉េចមិនហៅគ្រូអ៊ំនិងក្មួយ ?

នេះជាពាក្យបន្ទោសដ៏ស្និទ្ធស្នាលដែលហូរចេញពីទឹកចិត្តស្នេហាដ៏ត្រៀមនៃរវាងម្ដាយនិងកូន ។

## វគ្គទី ២៦

## អតីតកាលដ៏ស្មុគស្មាញ

ឥសីតានស៊ីជកជង្ហើមធំ :

- ហ៊ឹ ! រលកក្រោយច្រានរលកមុនមែន ! ពួកយើងចាស់ហើយ, ប្រើការមិនបានទៀតទេ !

វុនយូសើចហើយពោលបន្ត:

- កូនយើងខ្វះការគួរសមចំពោះគ្រូអ៊ំហើយ , ឆាប់សុំទោសគាត់ភ្លាមទៀត !

មាណពឆ្លើយបាទ គ្រវាត់កាំបិតចោល ប្ដូរទៅឱនកាយសំដែងការគោរព យ៉ាងស្មោះចំពោះតានស៊ី ។

វុនយូត្រេកអរណាស់ ពោលជំនួស:

- លោកបងនាយក្រុម , នេះកូនក៏ហ្លួបរបស់យើងខ្ញុំណា ! ដោយហេតុវាបែកពីខ្ញុំតាំងពីតូច បានជាមិនដឹងខុសត្រូវអ៊ីចឹង ។

ឥសីតានស៊ីភ្ញាក់ក្រញាង :

-អូ ! ជាបុត្ររបស់ប្អូនស្រីឬ ? អម្បាញ់មិញប្អូនថាបុត្រនេះត្រូវគេចាប់ទៅបាត់...ប្អូនកុហកទេហ៎ះ ?

ស៊ីឈីនប្រញាប់ឆ្លើយបញ្ជាក់ថា:

- ខ្ញុំម្ដេចនឹងហ៊ានកុហកលោកបង ? ការពិតបុត្រនេះត្រូវគេចាប់មែន, តែមិនដឹងហេតុអ្វី វាត្រឡប់មកណា ! អម្បាញ់មិញបន្ទាន់ពេកគេសួរបញ្ជាក់វាមិនទាន់ ។

ឆានស៊ីងកក្បាល :

-ត្រូវហើយ, លោកតាមគំនិតយុទ្ធសិល្បៈនិងកម្លាំងកាយ ក្មេងនេះអាចរត់រំដោះខ្លួនដោយងាយ ៗ ប៉ុន្តែក្មួយប្រុសប្រើស្នៀតគុនខុសប្លែកពីប្អូនប្រុសប្អូនស្រីឆ្ងាយណាស់ ថែមមានស្នៀតគុនដាវក្រុមភ្នំទឹកគកលាយឡំផង ៗ គួរឲ្យឆ្ងល់ជាពិសេសត្រង់ស្នៀតប៉ុន្មានក្រោយដែលមិនធ្លាប់ជួបប្រទះសោះ ៗ

ស៊ីផឆានឆ្លើយភ្លាម :

-បាទ, ស្នៀតនេះអាស៊ីវបង្ហាត់ខ្ញុំ ៗ នាងប្រាប់ខ្ញុំថា «បើគេវាយចាញ់បង បងត្រូវចេះអធ្យាស្រ័យខ្លួនផង បើកាចរៀសវាក៏បានត្រូវសង្កោស» ៗ ស្នៀតនេះបានឈ្មោះថា ក្មេងស្លាបស្លាំ អាចទុកកិត្តិយសឲ្យសត្រូវផង, អាចការពារខ្លួនឯងបានផង ៗ

ហេតុតែស្លូតហើយស្មោះត្រង់តាំងពីដើមមក នាយពុំសូវរវល់នឹងគេទេ នឹកឃើញយ៉ាងណានិយាយយ៉ាងនោះ ធ្វើឲ្យមុខឥសីឆានស៊ីប្រែសម្បុរក្រហមឆ្អិន ដោយក្តីអៀនខ្មាស ៗ ស៊ីឈើងស្រែកសន្ធាប់ :

- ឈប់មាត់ ! ម៉េចឯងនិយាយផ្តេសផ្តាសម្លេះ !

- បាទ , ខ្ញុំ... ខ្ញុំឈប់និយាយហើយ ៗ បើខ្ញុំដឹងមុនថាគាត់យកខ្សែចងដៃមានពិសនេះដាក់ហើយប្រើតែកាំបិតប្រយុទ្ធប្រហែល ... ប្រហែលជា ... ;

នាយនឹកឃើញថា បើសារភាពថានាយបានសម្លាប់ឥសីពីររូប ច្បាស់ជាមានការរឹករវរទៀតពុំខាន ម៉្លោះហើយនាយឈប់មាត់ភ្លាម ៗ ប៉ុន្តែសំដីមុនក្រោយនេះបានបណ្តាលឲ្យឥសីទាំងអស់ភ្ញាក់ផ្អើលស្រែកសួរនាយផុំទិស :

- បាតដៃឯងមានជាតិពិសឬ ?:

- លោកបងចាវស៊ីឌិងបុងស៊ីត្រូវឯងសម្លាប់ឬ ?

- ផ្កាកបញ្ញាតឹងឯងលួចមែនទេ ?

ឥសីពលរូបដកដាវពីស្រោមខ្លាកៗ ចេញមកកាន់គ្រប់ដៃវិញ, ស៊ីផឆានផ្អកផ្អើមយ៉ាងវែង ឆ្លើយមួយៗ:

-ខ្ញុំគ្មានបំណងសម្លាប់គាត់ទេ គ្រាន់តែលើកដៃឡើងលើ, ពួកគាត់ដួលប្រូសដែនកំពីកភ្លាម ៗ ឥសីឈុងស៊ុំខឹងប្រាឡាត ងាកមកប្រាប់ស៊ីឈើង :

- ប្អូនស៊ី, រឿងហ្នឹងគិតយ៉ាងណាស្រេចតែប្អូនទេ ។

ស៊ុំឈីងខ្វល់ខ្វាយណែនទ្រូង បែរមើលកិរិយាបេញអ្នកស្រីហូរទឹកភ្នែកសស្រាក់ ដោយការស្តុតស្មារតី ។ គាត់ពោលយ៉ាងដាច់ណាត់ថា :

-គុណគ្រូធ្ងន់ណាស់, អាត្មាបាននេះបង្ករឿងហេតុគ្រប់ពពួក រកតែប្ដីប្រពន្ធខ្ញុំស្រោចស្រង់មិនរួច ហេតុនេះសុំលោកបងនាយក្រុមចាត់ចែងតាមត្រូវការចុះ ។

ឈុនស៊ីងក់ក្បាលឆ្លើយថាល្អ ! ហើយលោសសាវប្រុសស្ទុះចូលទៅ ។ អ្នកស្រីនុនយូស្រែកឃាត់:

- ឈប់សិន !

ឈុនស៊ីងាកសួរទាំងសោះកក្រោះថា :

- ប្អូនស្រីចង់និយាយអ្វីទៀត ?

នុនយូពោលទាំងរអាក់រអួល :

- ពេលនេះលោកបងចាប់ស៊ីងនិងប៉ុងស៊ីមិនទាន់ឃាត់ឡើយទេ, ប្រហែលអាចក្បាលបាន ។

ឈុនស៊ីងើយមើលមេឃសើចហាសៗ :

- ប្អូនចាំងតើត្រូវពិសក់ណាចងល់ម្ដងហើយទៅសង្ស័យអ្វីទៀត ? ប្អូនស្រីនិយាយនេះពិតជាហាក់ត្កុកតំប៉ែងហើយ !

នុនយូដឹងថាគ្មានសង្ស័យទៀត តែគាត់ងាកសួរមាណព :

- កូន , បាតដៃកូនមានជាតិពិសពុលណា ? មានថ្នាំបន្សាបទេ ?

អ្នកស្រីសួរផងដើរទៅជិតផង :

- ឲ្យម៉ែមើលមើល ! កុំហៅថាមានថ្នាំបន្សាបឬទេ ?

អ្នកស្រីធ្វើជាលូកដៃកុំហៅថាមាណព តែគាត់ធ្មេចខ្សែបង់ក្រវៀកមាយ

- ចាប់តែនេតភ្ជាមទៅកូន ! ពុកម៉ែងមិនជួយកូនលែងបានហើយ ។

មាណពភ្ញាក់ផ្អើលស្រែកភ្ញាក់សម្លេង :

- ពុកម៉ែង ? អ្នកណាជាពុកម៉ែងខ្ញុំ ?

ក្បួនសម្បាញមិញនាយពុតសីសួរថា "បុត្រៗ" នាយមិនដឹងថា "បុត្រ" ជាកូន រីការដែលប្ដីប្រពន្ធស៊ុំឈីងហៅនាយថា "កូនៗ" នាយស្មានថាបាស់ទុំនិយាយមកកាន់ក្មេងៗត្រូវហៅម្ដងខ្លះឯង ។

ណាយមានដែលស្មានថាពូរមាក់នេះប្រែឡនាយជាកូនគេឯណា ?

ក្នុងពេលជាមួយបានវត្តរឹងសង្កត់ក្នុងនាយជាប់គឺស៊ីឈើនរុញចុងដាវចុចដីពបរមែនឲ្យនាយរត់ :

- កូនយូ, យើងមិនត្រូវបណ្តោយឲ្យកូនចង្រៃនេះធ្វើខូចកិត្តិយសក្រុមបក្សទេ ។ កុំឲ្យវា រត់គេចទៀត :

សម្លេងនេះមានភាពថ្ងូរចត់ណាស់. អ្នកស្រីវុនយូវិញក៏ឃ្លៅណែនបំពង់កតឹងទ្រូងចង់ដឹងមុខ ផ្លូលសន្ធប់តែគាត់ទំនួរសួរមាណពទៀតដោយសម្លេងញ័រៗ:

- កូនប្រុសពិតជាគ្មាន ... ជ្រាបឲ្យបពិសសម្រាប់ជួយព្យាបាលគ្រូអំពាំងពីរមែនឬ ?

ឥសីលឹងស៊ុំឈរវាក្យនោះ សង្កេតទឹកមុខអ្នកស្រីឃើញប្រែប្រួលញាំក្នុងប់ពេកគាត់ទឹកឬ :

- ចិត្តស្រីមើលមិនយល់ទេ, ប្អូននេះកេចកាំងយើងមិនឲ្យប្រហារកូនប្រុសផង កេចធ្វើអត្តឃាត ផង ។ គិតដូច្នោះហើយគាត់លូកដៃកញ្ចក់ដាវអ្នកស្រីបាត់ក្លាប ។ វុនយូរលៃមាណព ម្នាក់គត់មិនអើពើដឹងនៅណា ចាំងអស់, ម្លោះហើយឥសីលឹងស៊ុំឥល្ហើមដាវគាត់បាត់យាំងអាយ ។ ស៊ុផានឃើញដូច្នេះស្រែកគំហក :

- លោកកបង់ធ្វើអី ?

ស្រួតផង លូកដៃប្រុងដណ្តើមដាវអ្នកស្រីមកវិញ លឹងស៊ុំត្រវាត់ដាវកាប់ដៃនាយក្លាប តែមាណព ទម្លាក់ដៃថ្លក់ដៃគាត់តាមស្នៀតបាប់ខ្ញាំដែលទីងកុងបង្ហាត់ បានក្លាមដែរ ។ ស្នៀតបាប់ខ្ញាំនេះ រហ័សអស្ចារ្យមែន តែមិនកេចឈ្នះអ្នកក្លាហាននៃកស្រុបសាំងឈើងឡើយ ។ ឥសីលឹងស៊ុំស្រែក រ៉ាស បង្វិលដាវត្រូសកាត់ក្លួត ហើយស្រាប់តែស្រែកខ្លួនថ្លួលប្រួប ។

នេះជាឥទ្ធិពលដាត់ពិសកុង់បាត់ដៃមាណពទៀតហើយ ។ នាយបាប់ខ្ញាំផង ឥសីហាមាត់ ស្រែកផង ទើបស្រូបដាត់ពិសកំណាចមួយផ្ញើបចផ្លូលសន្ធប់ក្លាម ។ ហេតុការណ៍ថ្មីនេះធ្វើឲ្យឥសី តាំងអស់ភ្ញាក់ផ្អើលបួងទៀត ហក់ថយក្រោយរៀងខ្លួនដោយទឹកមុខស្លេកស្លាំងដូចជួប ខ្មោចបិសាច អសុរកាយ ។

ស៊ុផានមិនមែនសប្បាយទេ, ខាយទឹកថាគ្រោះថ្នាក់កាន់តែកើនឡើងហើយ, ប៉ុន្តែរត់គេច មិនរួចដែរ ព្រោះពួកឥសីឈរព័ទ្ធជុំវិញកាន់ដាវសស្កាច ។ ប៉ុន្តែគេបានតែបម្រាមមនុស្សអត្តឃាយ ទៀតហើយ ។

Khmer Story Lovers



នាយក្រឡេកមើលលីនស៊ី ឃើញឥសីរូបនេះទុបពោះរមួលខ្លួនដូចឈឺខ្លាំងណាស់ ទ្រាំមិនបាន... ត្បិតឥសីខាងអាស្រមសាំងឈឺង មានកម្លាំងធាតុជ្រៅជ្រះជាងក្រុមច្បូកដែក ដែលហិតក្លិនពិសដួលស្លាប់ទាន់ហន់ ម្ល៉ោះហើយគេអាចទ្រាំទ្របានមួយរយៈពេល តាមកម្រិតរៀងខ្លួន និងតាមចំនួនក្លិនពិសកំណាច ។

មាណពមើលឥសីលីនស៊ីស្រវៃឃើញចាន់សានទន់លំទ្រើតទុបពោះក្នុងបន្ទប់ក្រោមដី របស់ក្រុមច្បូកដែក, ទឹកឃើញចាន់សានប្រើនាយឲ្យសង្កត់ជីពចរជំរុញពិសមកក្រៅតាមបាតដៃម្ខាង នាយស្ទុះក្លេតទៅលើកឥសីឲ្យអង្គុយស្រួលបួលភ្លាម ។ ផ្ទៃថ្ងាឥសីជះពន្លឺផ្ទេកៗ ប្រេងចាក់សំរុកមក តែនាយមិនរវល់ឡើយខំស្រូតរូតជួយជីវិតលីនស៊ីដោយដាក់ដៃផ្ទេនលើជីពចរខ្នង, ដៃស្តាំសង្កត់ចុងដង្ហើមលីនស៊ី ធ្វើដូចដែលចាន់សានប្រាប់ ។ មួយសន្ទុះធំឥសីលីនស៊ីដកដង្ហើមវែងស្រែកជេរ:

- យើស! អាចោរគេដោតនេះកាចសាហាវណាស់!

អ្នកទាំងអស់គ្នាស្រែកឆោឡោភ្លាម ទោះសំដីឥសីមិនសមសក្តិធំអ្នកបួសរៀនក៏ដោយ ។ គេត្រេកអរដោយដឹងថា គាត់រួចផុតគ្រោះថ្នាក់ហើយ ។

វុនយូអរពេកហូរទឹកភ្នែករហាម:

-កូនប្រុស, គ្រូអឺចាវស៊ីនិងចុនស៊ីត្រូវពិសមុនណា! ជួយព្យាបាលគាត់ឆាប់ឡើង!

ឥសីពីររូបមិនបង្អង់យូរ រត់ទៅលើកគ្រាហ៍ចាវស៊ីនិងចុនស៊ីមកដាក់ចំពោះមុខមាណពភ្លាម ។ ស៊ីផានជួយជំរុញពិសតាមមធ្យោបាយដដែល ។ ឥសីពីររូបនេះសន្លប់បាត់ស្មារតីយូរពេកទាល់តែមាណពចំណាយកម្លាំងធាតុអស់ពេលដ៏យូរ ទើបឥសីចាវស៊ីភ្ញាក់ដឹងខ្លួន ស្រែកជេរតែម្តង :

- យើស! អាក្មេងចង្រៃនេះ!

ឥសីចុនស៊ី ក៏ស្រែកជេរដែរ :

- កូនឥតពូជហ៊ានប្រើថ្នាំពិសផងវ៉ី!

ប្តីប្រពន្ធស៊ីលើងត្រេកអរពន់ប្រមាណឥតយកចិត្តទុកដាក់នឹងសំដីឥសីទេ, ទោះគាត់ពោលពាក្យមិនគប្បីចំពោះខ្លួនក៏ដោយ, តែគេអស់សំណើចដូចគ្នានឹកថា:

- លោកបងឥសីទាំងពីរទាំងបីធ្លាប់តែធ្វើមុខមាំកាន់ពាក្យសច្ចៈខន្តីសមជាអ្នកកាន់សីល, ដល់ពេលបានសន្លប់ម្តងចេះជេរផងហ៎ា!

អ្នកស្រីវ៉ុនយូពោល :

– នែកូនប្រុស, បើកូនយកផ្កាកស្ពាន់ពីគ្រូគីតារស៊ីមែន, ប្ដូរកូនជូនគាត់វិញចុះ, ម៉ែលែងចង់បានហើយ ។

មាណពភ្ញាក់ព្រើតពោលរអ៊ូម្នាក់ឯង:

– ម៉ែ...ម៉ែ...

នាយលូកយកផ្កាកស្ពាន់ពីហោប៉ៅប្រគល់ជូនឥសីព្រមទាំងពោល

–ម៉ែ...ម៉ែ..ខ្ញុំជាអ្នកណាមួយ ?

ឥសីធានស៊ីផកផ្ដើមចំប្រាប់ស៊ុយឈីននិងវ៉ុនយូ :

–ប្អូនប្រុសប្អូនស្រី, យើងល្មមបែកគ្នាត្រឹមណេះចុះ !

លោកឥសីយល់ថា ប្រហែលលែងបានជួបប្អូនរួមគ្រូពីរនាក់ប្ដីប្រពន្ធនេះទៀតហើយ បានជាគាត់មិនបន្តថា «ថ្ងៃក្រោយយើងជួបគ្នាទៀត» ។ ឥសីពោលតែប៉ុណ្ណោះក៏បបួលប្អូន ១ ចាកចេញពីទីនោះភ្លាមទៅ ។

ស៊ីផធានសម្លឹងអ្នកស្រីវ៉ុនយូធ្វើមុខមិនមាំនដោយងឿងឆ្ងល់ក្រៃពេក ។ អ្នកស្រីមានទឹកភ្នែករលីងរលោងខំពោលទាំងញញឹម :

– កូនចំកួតនេះហ្ន៎ !... កូនមិនស្គាល់ឪពុកម្ដាយទេឬ ?

ពោលតែប៉ុណ្ណោះអ្នកស្រីទប់ចិត្តមិនបានក៏ស្រវ៉ាឱបនាយយ៉ាំងតឹង ។

តាំងពីដឹងក្ដីមក មិនដែលមាននរណាចាប់ឱបថ្នាក់ថ្នមនាយអោយស្មោះបែបនេះទេ ។ មាណពរំភើបចិត្តណាស់ មិនដឹងពោលពាក្យអ្វីឲ្យសមសួនឡើយ ម៉្លោះហើយនាយនៅស្ងៀមមួយសន្ទុះទើបពោលរដាក់រដុប :

– លោកម្ចាស់ ... ស៊ីផាឪពុកខ្ញុំឬ ? ខ្ញុំឥតដឹងសោះទេ ។ ប៉ុន្តែ ... ប៉ុន្តែ ... លោកស្រីមិនមែនម្ដាយខ្ញុំទេ ខ្ញុំកំពុងរកម៉ែខ្ញុំដែរណា !

អ្នកស្រីឮមាណពពោលបែបនេះក៏ឈ្លួលចុងច្រមុះហូរទឹកភ្នែករហាមត្អូញថា:

– ឱ ! កូនប្រុសកំសត់អើយ ! ម្ដាយមិនត្រូវបន្ទោសកូនទេ .. យើងបែកគ្នាច្រើនឆ្នាំ ... កូនក្មេងពេកនឹងម៉ែអ៊ីចឹងហើយ ! កាលកូនចាកចេញពីភូមិបាំនសាំនស៊ូទៅរៀនយុទ្ធសិល្បៈកូនមាន

គំនាស់ត្រឹមទ្រូងម្ដាយសោះ, ឥឡូវនេះកូនធំជាងខ្ពស់ជាងឪពុកទៅទៀត ។ មុខមាត់កូនក៏ប្រែសន្ធឹកដែរ. . . កាលជួបគ្នាក្នុងពេលកញ្ចាស់ពុកនឹងម៉ែមើលកូនឥតស្គាល់ទេ, បើកុំតែដំនឹងថា ប៉ាយកាន់ជានចាប់កូនយកទៅពុកនឹងម៉ែប្រឡំធំហើយ ។

មាណពស្ដាប់យូរតែឆ្ងល់ៈឡើងពិចារណាថា :

- ប៉ាយកាន់ជានចាប់យើងទៅជាការពិតមែន តែម៉ែយើងមុខធំជាត់តាបជាងអ្នកស្រីស៊ី . . .

នាយរុញពកមួយស្របក់ទើបដាច់ចិត្តពោលថា :

- លោកស្រីស៊ីប្រឡំហើយ , ខ្ញុំ . . . ខ្ញុំ . . មិនមែនជាកូនប្រុសលោកស្រីទេ !

អ្នកស្រីឆាកសួរស្វាមី:

- បងឈើង , បងមើលកូននេះ . . .

ស៊ីឈុនឈរស្ងៀមស្ងាត់ស្ដាប់សំដីមាណពគាត់ពិចារណាដែរថា :

- កូននេះខិលខូចល្បីពេញមួយក្រុមក្នុងកកកពិតជាបានកលល្បិចអ្វីមួយ ទើបមិនព្រមទទួលស្គាល់ឪពុកម្ដាយ ។ ឬមួយវាខ្មាសអៀននឹងអំពើថោកទាបដែលបានប្រព្រឹត្តនៅក្នុងកកក ? ឬមួយវាដើរសាបព្រោះអំពើបាបក្នុងក្រុមឈានលួចតាល់តែខូចកេរ្តិ៍ឈ្មោះមិនហ៊ានជួបមុខឪពុកម្ដាយ ? ឬវាខ្លាចយើងជេរស្ដី, ខ្លាចឪពុកម្ដាយកើតគ្រោះដោយសារវា ?

ស៊ីឈើងសួរម្ដង :

- កូនជានាយក្រុមឈានលួចត្រកូលស៊ីមែនទេ ?

មាណពអេះក្បាល :

- ហ៊ឺ ! ក្រុមឈានលួចេះតែថាខ្ញុំជានាយក្រុមស៊ី ការពិតគេប្រឡំទាំងអស់គ្នាហ្នឹង !

- បើអ៊ីចឹងឯងឈ្មោះអីដែរ ?

មាណពធ្វើមុខស្លូហាក់លែងយល់អ្វីទាំងអស់ :

- ខ្ញុំគ្មានឈ្មោះគ្មានត្រកូលនឹងគេទេ ។ ម៉ែខ្ញុំហៅអាក្ដែឥតពូជតាំងពីដើមមក ។

ស៊ីឈើងងើបមើលមុខភរិយាឲ្យសញ្ញាដើរចេញពីនោះបន្តិច ។ គេមើលមុខមាណពជឿជាក់ថា នាយពោលដោយស្មោះអស់ពីពោះឥតមានកុហកឡើយ ។ ស៊ីឈើងពោលតិចៗ :

- អូនយូ , ក្មេងនេះពិតជាជុនយីមែនឬ ? យើងស៊ើបដឹងថា វាជានាយក្រុមឈានលួច,

បើធ្វើនាយក្រុមនឹងគេដែរ ម៉េចក៏ល្ងីល្ងើអ៊ីចឹង ?

អ្នកស្រីពោលទាំងអណ្ដើតអណ្ដក :

- កូនយើងបែកពីយើងជាងដប់ឆ្នាំហើយ , ក្មេងចម្រើនវ័យតែងមានការប្រែប្រួលទាំងរូបកាយទាំងចិត្តគំនិត តែ.. ខ្ញុំនៅយល់ថា វាពិតជាកូនប្រុសខ្ញុំហើយ !

ស៊ីឈីងសញ្ជឹងគិតបន្តិច :

- អូនពិតជាគ្មានសង្ស័យកន្លែងណាសោះទេឬ ?

- សង្ស័យដែរ តែ... មិនដឹងហេតុអីខ្ញុំជឿ.. ជឿជាក់ក្នុងចិត្តថា វាពិតជាកូនយើងណា ! ដូចជាមានអ្វីមួយប្រាប់ខ្ញុំថាវាជាកូនខ្ញុំ.. រកនិយាយមិនបានទេ ។

ស៊ីឈីងនឹកឃើញរឿងមួយក៏សួរបែបភ្ញាក់ថា :

- អូនឃូ ! នៅចាំដែរកាលថ្ងៃស្រីចន្រ្ទានោះធ្វើបាបអូន ?

ប្ដីប្រពន្ធស៊ីឈីងមានរឿងដូចតមួយប្រចាំជីវិតជិតជាប់អារម្មណ៍អ្នកស្រីវុនឃូរាល់ពេលវេលា តែគេមិនហ៊ានរំឭកនាំឲ្យឈឺចាប់ឡើយ ។ ស៊ីឈីងសួរតែប៉ុណ្ណោះ ក៏ឈប់ស្ងៀម, វុនឃូភ្ញាក់ព្រើត:

- ខ្ញុំមិនដែលភ្លេចរឿងនេះទេ ។ ចាំខ្ញុំទៅសួរវាមើល ?

អ្នកស្រីដើរទៅរកមាណពវិញដាក់គូទអង្គុយលើជុំ ហើយទាយដៃហៅ :

- កូនប្រុសមកណេះម៉ែនិយាយរឿងមួយ ។ ស៊ីផានដើរតម្រង់ទៅ, អ្នកស្រីចង្អុលផ្ទាំងថ្មមួយដុំឲ្យនាយអង្គុយក្បែរនោះហើយចាប់ផ្ដើមពោល:

- កូនអើ ! កាលឯងទើបបានអាយុពីរឆ្នាំមានចោរស្រីម្នាក់ចង់សម្លាប់ម៉ែដល់ក្នុងផ្ទះ ។ ថ្ងៃនោះពុកឯងមិននៅទេ, ចំណែកម៉ែទើបសម្រាលកូនប្រុសមួយទៀត មិនទាន់បានមួយខែម៉ែឥតកម្លាំងតទល់នឹងមេចោរកំណាចឡើយ ។ ចោរស្រីនោះសាហាវណាស់, វាចង់សម្លាប់ទាំងម៉ែ, ទាំងរូបកូននិងប្អូនប្រុសឯងដែលទើបកើតក្រហមរងាលទៀត !

មាណពភ្ញាក់ព្រើតសួរ :

- ចុះវាសម្លាប់ខ្ញុំបានទេ ?

តែនាយក្ដាប់មាត់ពោលបន្ត :

Khmer Story Lovers



– ខ្ញុំល្ងើវល់ហើយហ្ន៎ ! បើខ្ញុំស្ដាប់ម៉េចមកអ្នកនិយាយគ្នាកន្លងទៅនេះបាន ?

អ្នកស្រីបន្ទរទាំងមុខស្រងូត :

–កាលណោះម៉ែពពោះផ្ទៃប្អូន, គាត់ដាវប្រយុទ្ធនឹងមេចោរអម្រិយដៃម្នាង, ចោរស្រីនោះខ្លាំងពូកែណាស់ តែទេវតាជួយ,ក្នុងគ្រាអាសន្ននោះឪពុកឯងត្រឡប់មកទាន់, ម៉េចោរនោះចោលអាវុធសម្ងាត់ប្រាក់កាត់រាប៉ឺតម្រង់មក ។ ម៉ែវាយផ្កាត់អស់ពីរ នៅសល់គាត់ចំប៉ះហើយលឿនស្ទើរប៉ះកំប៉េះគូទកូនពុំពឹក កូនស្រែកយំរ៉ា ។ ម៉ែហេវហត់ផងភ័យផង សន្លប់បាត់ស្មារតីទៅ ... ចោរស្រីសាមាឡ ឃើញពុកឯងមកដល់រត់គេចភ្លាម ថែមទាំងចាប់ប្អូនប្រុសឯងយកទៅផង, ពុកឯងរវល់មើលម្ដាយ ឥតបានដេញតាមវាទេ ។ ម្យ៉ាងទៀតយើងនឹកថាចោរស្រីនោះមិនដាច់ចិត្តសម្លាប់ទារកទេ, ប្រហែលវាបំភ័យយើងប៉ុណ្ណោះ ។ កូនអើយ ! ចោរស្រីមនុស្សឃោរឃៅ! បីថ្ងៃក្រោយមកវាបញ្ជូនសាកសពប្អូនប្រុសឯងមកឲ្យម្ដាយវិញដោយមានដាវខ្លីពីរដោតជាប់លើទ្រូងវាផង ... ដាវមួយពណ៌សមានចារឈ្មោះឪពុកឯងនិងម៉ែផង ... ហេតុនេះ...

អ្នកស្រីស្អួលអាក់ពេញខ្នះ ហាមាត់និយាយតទៅទៀតលែងរួច, ទឹកភ្នែកហូរហោរហាមជោគថ្ពាល់ ៗ ស៊ីផានសម្ងំស្ដាប់ដល់ចប់ ទើបស្រែកទាំងគ្រវក្រោធ :

– ចោរស្រីណានោះកាចសាហាវមែន ! កូនក្មេងដំរឹស្ទើរ, ម៉េចក៏សម្លាប់ចោល ? ហ៊ឺះ ! បើមិនមានរឿងអាក្រក់បែបហ្នឹង ខ្ញុំមានប្អូនប្រុសមួយនឹងគេហើយ ។ តែ.. លោកស្រីស៊ុ, រឿងនេះម៉ែខ្ញុំមិនដែលនិយាយប្រាប់ទេ ។

វ៉នយូហូរទឹកភ្នែកកាន់តែច្រើន :

– កូន...កូនពិតជាក្មេងម្ដាយបង្កើតមែនឬ ? ម៉ែ.. ម៉ែនេះហើយជាអ្នកបង្កើតកូនមកណា !

ស៊ីផានសម្ងំមុខអ្នកស្រីគ្រវីក្បាលម្ដងៗ:

– មិនមែនទេ, លោកស្រីច្រឡំហើយ !

អ្នកស្រីខំពោលទាំងស្អួលអាក់ :

– ថ្ងៃនោះចោរស្រីកំណាចចោលប្រាក់កាត់ត្រូវកំប៉េះគូទកូនខាងឆ្វេង, ទោះកូនធំប៉ុណ្ណេះហើយក៏នៅមានស្នាមដែរ ។ ចូរកូនស្រាយខោមើលមើល !

ស៊ីផានភ័យស្មារតណាំតអ្នកស្រីផងពិបាកចិត្តខ្លួនឯងផង នឹកដល់ស្នាមក្លាញ់ចង្កូមលើស្មា ទិន

ស្នាមផ្លាំទឹកកក ដែលជាក្រុមភ្នំទឹកកកដ៏តក្រៃឡើងលើជើង ។ ហើយមុននាយផឹកដឹងសោះស្រាប់តែដោះការឃើញស្នាមជ្រួញ, ម្ដងដើរទៅឃើញស្នាមជាំ ! ហើយអស់នេះនាយមិនទាន់យល់នៅឡើយ ។ ឥឡូវនេះលោកស្រីស៊ុំប្រាប់ថាមានស្នាមប្រាក់កាត់បើកបេះដូងទៀតហើយ ! ឬហេតុមានបែបនេះមែន ?

នាយស្ទាបស្ទង់ពីក្រៅខោឥតប៉ះស្នាមអ្វីសោះ តែហើយពីមុនជាក់ស្ដែងពេក ទើបនាយមិនទុកចិត្តខ្លួនឯង ។ វ៉ុនយូឃើញមាណពមានទឹកមុខខុសប្លែកពីប្រក្រតី ហាក់ភ័យណាស់ក៏ខំញញឹមតៀន :

– ម៉ែបង្កើតកូនមកព្រាប់ប៊ីបមថ្នាក់ថ្នមថ្នាស់កំណាត់កាចម៉ៅខោបគាំងពីតូចមក , កូនទៅខ្មាសអៀនអីទៀត ? ណ្ហើយ , ទៅឡើងពុកឯងជួយមើលចុះ ។

ពោលហើយអ្នកស្រីដើរចេញឆ្ងាយពីនោះ , ស៊ុំឈើងើបង់ផឹងក្បាល ៗ ដែរក៏ពោល :

– កូនស្រាតខោបន្ដិចមើលខ្លួនឯងទៅ ។

ស៊ុំផាត់ស្ទាបស្ទង់ពីក្រៅខ្លួនទៀតឥតប៉ះស្នាមគគ្រាតគគ្រើមអ្វីសោះ ទើបប្រថុយស្រាយបន្ទោះខោងាកមើលកំប៉េះគូទ ។ នាយភ្ញាក់ភ័យឥតឧបមា កាលបើឃើញស្នាមមួយប៉ុនមេដៃលើគូទខាងឆ្វេង ។ ស្នាមនេះមិនសូវច្បាស់លាស់មែន តែមាណពវីលវល់អារម្មណ៍ក្រៃលែងដូចដែនដីពុំងក្រឡប់ផ្កាប់ផ្ងារ ការឡើងនាយឲ្យទៅជាបុរសម្នាក់ទៀត ដោយហេតុនាយមិនដឹងខ្លួនមានអ្វីខ្លះទៀតទេ ។ មាណពកិតភ័យពេកទ្រាំមិនបានស្រែកទ្រហោយំដូចកូនក្មេង ។

អ្នកស្រីវ៉ុនយូងាកក្រោយខ្ទប់មើលមុខស្វាមី ឃើញស៊ុំឈើងងក់ក្បាលញញឹមរកបានសេចក្ដីថា អ្នកម៉ោះនេះជាកូនភូនយីរបស់គាត់មែន ។ អ្នកស្រីត្រេកអរជាង ពិបាកថាង របាយទៀតគ្នាសួរបួលចាប់ថុបមាណពស្រូបទឹកភ្នែកហើយលួងលោម :

– កូនយី, កូនមាសម្ដាយ ! កូនកុំខ្ចាចអីនោះមានហើងអ៊ីបុណ្ណាក៏ពុកនិងម៉ែហ៊ានលាខាកប់ដើម្បីជួសកូនដែរ ។

ស៊ុំផាត់តបវិញទាំងទឹកភ្នែក :

– ហើងតាស់ទាំងប៉ុន្មាន ខ្ញុំនឹកមិនឃើញទេ ។ ខ្ញុំ នដឹងថា ម៉ែជាក្ដាយបង្កើតខ្ញុំមកទេ.. មិនដឹងនណាជាឪពុក ហើយ...មិនដឹងកូនខ្លួនមានស្នាកស្នាមអីខ្លះ ។ ខ្ញុំ...ខ្ញុំមិនដឹងអ្វីទាំងអស់ .

ស៊ុំឈើងទៀតសួរ :

– ចុះកូនបាត់បានគម្ពីងជាក់ស្ដែកម្លួនេះពីណាមក ?

– ខ្ញុំមិនដឹងទេ ។

ស៊ីឈើងសួរថែម :

– វិជ្ជាបាតដៃពិសេសនេះ ទើបនឹងហាត់ពេលថ្មីៗ ឬ ? អ្នកណាបង្ហាត់ឯង ?

ស៊ីផានភ្ញាក់ក្រញាង:

– គ្មានអ្នកណាបង្ហាត់ខ្ញុំទេ .. យ៉ាប៉ាបីប្រេះ ? ខ្ញុំល្ងីល្ងើខ្លាំងហើយ .. ឬមួយខ្ញុំជាស៊ីផាន? ជានាយក្រុមស៊ីអីគេនោះមែន ? ស៊ី ... ស៊ី .. ខ្ញុំបានត្រកូលស៊ី ... ខ្ញុំជាកូនប្រុសរបស់លោកឬ ?

នាយក័យស្ងាំងមុខញើរមាត់ទទ្រើកខំចាប់ចង្កេះខោកុំឲ្យរបូតហើយឈរត្អើងញើមុខប្តី ...

ប្តីប្រពន្ធស៊ីឈើងឃើញនាយក័យភ្លេចខ្លួនដូច្នេះ ទៅជាស្រទន់ចិត្តម្នាក់ៗពរៈដែរ ។ អ្នកស្រីនុយុកណិតនាយខ្លាចចិត្តលូកដៃរម្ហែលក្បាលនាយយ៉ាងថ្នមពោលដោយទន់ភ្លន់:

– កូនប្រុសម្តាយកុំភ័យ , កុំខ្លាចអី ។

ស៊ីឈើងទុកកំហឹងចាស់មួយអន្លើពីរណា ថា:

– យើងចាប់ពុតចាស់ ។ និយាយកៀតបុស្សក្ដេចតែពីកាលខ្ញុំខ្លួនក្រោយពីលើប៉ាទមន្តបុត្រគេរាយសំពងឡប់ស្មារតី , ដប្លូនេះហៅថា «ដប្លូគ្មានព្រលឹង» ពីបាកព្យាបាលណាស់ ។ ឬមួយ .. កូនយើងមានជម្ងឺបែបនេះ ?

ស៊ីឈើងនឹកឃើញរឿងនេះឥតហានប្រាប់ភរិយាទេ , តែនុនបុកកុំពុងនឹកដូចគាត់ដែរ ។ ប្តីប្រពន្ធមើលមុខគ្នាពុះឡើងមួយស្របក់ ទើបស្រែកព្រមគ្នា :

– ដប្លូគ្មានព្រលឹង !

ស៊ីឈើងដឹងទៀតថា អ្នកណាបានជម្ងឺបែបនេះ គេមិនត្រូវបន្ទំសាកសួរឡើយខ្លាចរបើបរើនាំពិបាកព្យាបាលលើសដើម, គេត្រូវសួរស្តាបស្ទង់ពាក្យរាវនោះ ឲ្យអ្នកជម្ងឺនឹកឃើញរឿងចាស់ដោយខ្លួនឯងទើបមានសង្ឃឹម ម្ល៉ោះហើយគាត់ពោលពីរឿងផ្សេងថា :

– ថ្ងៃនេះគ្រួសារយើងបានជួបជុំមូលត្រកូល គឺជាថ្ងៃសិរីជ័យមង្គលសម្រាប់យើងហើយកូនប្រុស ! តឡូវកូនយើងឃ្លានបាយណាស់មើលទៅ, តិតរកបាយចឹកសិន ។

Khmer Story Lovers

(នៅមានត)